- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** ត្រូវបានផ្ទេរឥណទានចំនួន ២.៧០០លានរៀល(ពីរពាន់ប្រាំពីររយលានរៀល) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកជាផលប្រយោជន៍ ជំពូក ៣០(អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច) របស់ក្រសួងពាណិជ្ជកម្ម ក្នុងរង្វង់ថវិកាទូទៅ របស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខា តទៅ ។

**នាយករដ្ឋមន្ត្រីទី ១**
**ព្រះហស្តលេខានិងត្រា**
**នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហត្ថលេខា និងត្រា**
**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ០៤ អនក្រ.

## ស្តីពីការបង្វែរឥណទាន

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស /រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស/រកម/ ០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** : ត្រូវបានបង្វែរឥណទានពីជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់)ចំនួន ៦០លានរៀល (ហុកសិបលានរៀល) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច)ក្នុងវង្វង់ថវិការបស់ក្រសួងពាណិជ្ជកម្មសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខានិងត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *